**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៤០ **អយក.**ប្រក

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថលនិងការអប់រំពីចម្ងាយ នៃក្រសួងអប់រំ យុវជន និងកីឡា ដែលហៅកាត់ថា "មជ្ឈមណ្ឌល អ.ឌ.អ.ច." និងហៅជាភាសាអង់គ្លេសថា Center for Digital and Distance Education ដែលហៅកាត់ជាភាសាអង់គ្លេសថា "C.D.D.E."។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់យន្តការគ្រប់គ្រង និងដំណើរការ នៃមជ្ឈមណ្ឌល អ.ឌ.អ.ច. និងការរៀបចំតួនាទី និងភារកិច្ចសម្រាប់មជ្ឈមណ្ឌល អ.ឌ.អ.ច.។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តន៍ចំពោះការអប់រំតាមបែបឌីជីថល និងការអប់រំពីចម្ងាយ ដែលមានគុណភាពនិងសមធម៌ ប្រកបដោយបរិយាប័ន្ន និងស្របតាមគោលការណ៍នៃការអប់រំពេញមួយជីវិត។

**ប្រការ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ រួមមាន ៖

- **ការអប់រំតាមបែបឌីជីថល** (Digital Education)៖ ជាសមាហរណកម្ម នៃប្រព័ន្ធផ្នែករឹងនិងផ្នែកទន់ នៃបច្ចេកវិទ្យាព័ត៌មានជាមួយនឹងទ្រឹស្តី និងការប្រតិបត្តិការអប់រំ ដើម្បីលើកកម្ពស់គុណភាព និងលទ្ធផល នៃការរៀន និងការបង្រៀន។ សមាហរណកម្មនេះផ្តោតលើសមាសភាគបួន រួមមាន ការផលិតមាតិកាឌីជីថលសម្រាប់ប្រើប្រាស់ក្នុងការរៀន និងការបង្រៀន ការចែកចាយមាតិកាឌីជីថលទៅកាន់សិស្សានុសិស្ស គ្រូបង្រៀន និងបុគ្គលិកអប់រំ ការរៀបចំបែបផែន នៃការរៀនដោយប្រើវេទិកាឌីជីថល និងការប្រមូល វាយតម្លៃ និងវិភាគទិន្នន័យ និងព័ត៌មាននៃការរៀន និងការបង្រៀនតាមបែបឌីជីថល។
- **អក្ខរកម្មឌីជីថល** (Digital Literacy) ៖ លទ្ធភាពក្នុងការទទួលបាន គ្រប់គ្រង ស្វែងយល់ សមាហរណកម្ម ទំនាក់ទំនង វាយតម្លៃ និងបង្កើតព័ត៌មាន ដោយមានសុវត្ថិភាព និងដែលសក្តិសមតាមរយៈបច្ចេកវិទ្យាឌីជីថល សម្រាប់ការរៀន និងការបង្រៀន។ អក្ខរកម្មឌីជីថល រួមបញ្ចូលសមត្ថភាពដែលស្ថិតក្នុងបំណិន និងពុទ្ធិផ្សេងៗគ្នារួមមានអក្ខរកម្មកុំព្យូទ័រ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ព័ត៌មាន និងសារព័ត៌មាន។
- **ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក** (E-Learning)៖ ប្រព័ន្ធ នៃការអប់រំមួយបែប ដែលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ ហើយដោយប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ ដែលមានកម្មវិធីសិក្សា មេរៀន វិធីសាស្ត្របង្រៀន និងវាយតម្លៃសមត្ថភាពសិស្ស និងលទ្ធផល នៃការសិក្សាដោយនិយាមច្បាស់លាស់។ ការអប់រំតាមប្រព័ន្ធ E-Learning អាចរៀបចំនៅក្នុង ឬ នៅក្រៅថ្នាក់ ហើយភាគច្រើន គឺប្រើប្រាស់កុំព្យូទ័រ អ៊ីនធឺណិត និងប្រើប្រាស់កម្មវិធីកុំព្យូទ័រ ដែលគ្រប់គ្រងដោយប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក។
- **ការអប់រំពីចម្ងាយ** (Distance Education)៖ ជាវិធីសាស្ត្រមួយ ដែលសិស្សានុសិស្ស និងគ្រូបង្រៀន អាចផ្តល់ការអប់រំ (ការរៀន និងការបង្រៀន) សម្រាប់ការអភិវឌ្ឍសម្បទាទាំង៤ ដោយពុំចាំបាច់មានវត្តមាននៅសាលារៀន ឬ ជួបជាមួយគ្រូដោយផ្ទាល់។
- **វេទិកាឌីជីថល** (Digital Platform)៖ ជាកញ្ចប់ឬក្បួនខ្សែមនៃប្រតិបត្តិការរបស់ប្រព័ន្ធកុំព្យូទ័រ ដែលសម្របសម្រួលដល់ការរៀបចំបង្កើត ការចែកចាយ ការប្រើប្រាស់ និងការប្រមូលព័ត៌មាន នៃការអប់រំឌីជីថល នៅលើមធ្យោបាយបច្ចេកវិទ្យាព័ត៌មាន។
- **មាតិកាឌីជីថល** (Digital Content)៖ ជាបណ្តុំ នៃឯកសារ សៀវភៅសិក្សា មេរៀន ផ្ទាំងរូបភាព សម្លេង ឬ វីដេអូ ដែលផលិត រៀបចំ រក្សាទុក ចែកចាយ និងប្រើប្រាស់នៅលើវេទិកាឌីជីថល។ សៀវភៅ ដែលត្រូវបានបញ្ចូលទៅក្នុងមាតិកាឌីជីថល ត្រូវបានហៅថា "សៀវភៅអេឡិចត្រូនិក" ឬ E-Book ហើយបណ្ណាល័យ ដែលមានផ្ទុកសៀវភៅអេឡិចត្រូនិក និងមាតិកាឌីជីថលដទៃទៀត ត្រូវបានហៅថា "បណ្ណាល័យអេឡិចត្រូនិក" ឬ E-Library។

- **ប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក** (LMS ឬ Learning Management System)៖ ជាបណ្តុំ នៃកម្មវិធីកុំព្យូទ័រ ដែលតម្លើងរួចរាល់សម្រាប់ប្រតិបត្តិការផ្នែករដ្ឋបាល ការទុកដាក់ឯកសារ ការតាមដានលទ្ធផលការសិក្សា ការធ្វើរបាយការណ៍វាយតម្លៃ ការធ្វើស្វ័យប្រវត្តិកម្ម និងការផ្តល់កម្មវិធីបណ្តុះបណ្តាលនិងអប់រំ។ បណ្តុំ នៃកម្មវិធីកុំព្យូទ័រនេះ ជាសមាសភាគស្នូល នៃការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក។ ប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក ត្រូវបានតម្លើង និងប្រើប្រាស់ដើម្បីកំណត់ចន្លោះប្រហោងនៅក្នុងការរៀន និងបង្រៀន ការប្រើប្រាស់ទិន្នន័យសម្រាប់ការវិភាគ និងការធ្វើរបាយការណ៍។
- **មជ្ឈមណ្ឌលទិន្នន័យ** (Data Center)៖ ជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលប្រើប្រាស់សម្រាប់តំឡើង និងតម្កល់ប្រព័ន្ធកុំព្យូទ័រ និងសមាសភាគរួមផ្សំទាំងឡាយសម្រាប់បញ្ជូន រក្សា ផ្ទុក និងបំប្លែងទិន្នន័យសារគមនាគមន៍។

## ជំពូកទី២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃមជ្ឈមណ្ឌល អ.ឌ.អ.ច.

### ផ្នែកទី១
### តួនាទី និងភារកិច្ច នៃមជ្ឈមណ្ឌល អ.ឌ.អ.ច.

**ប្រការ៥.-**

មជ្ឈមណ្ឌល អ.ឌ.អ.ច. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សាអេឡិចត្រូនិក និងការអប់រំឌីជីថល
- រៀបចំបង្កើតវេទិកាឌីជីថលសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការត្រួតពិនិត្យ និងកែលម្អវេទិកាឌីជីថល ដែលមានស្រាប់ និងបន្ថែម ឬ បង្កើតប្រព័ន្ធតួនាទីថ្មី ដែលមានភាពទូលំទូលាយ និងស៊ីជម្រៅ សម្រាប់បម្រើដល់ការផ្តល់សេវាអប់រំតាមបែបឌីជីថល
- ផលិតមាតិកាឌីជីថល ជាពិសេស គឺវីដេអូ នៃការបង្រៀន ដែលប្រកបដោយភាពច្នៃប្រឌិតមានអន្តរកម្មរវាងគ្រូ និងអ្នកទស្សនា ដែលមានគុណភាពខ្ពស់ ហើយឆ្លើយតបចំពោះការអប់រំបរិយាបន្ន ឬការអប់រំពិសេស
- ផ្តល់មាតិកាឌីជីថលដល់គ្រឹះស្ថានសិក្សា ដើម្បីអនុវត្តវិធីសាស្ត្របង្រៀនសតវត្សទី២១ ដូចជាប្រព័ន្ធនៃការសិក្សា ស្វ័យសិក្សា សិក្សាក្នុងថ្នាក់រៀន (Blended Learning) និងវិធីសាស្ត្រសិក្សាបញ្ច្រាប (Flip Classroom) ការធ្វើស្វ័យសិក្សាមុនការរៀនក្នុងថ្នាក់រៀន
- រៀបចំបង្កើត គ្រប់គ្រង និងចាត់ចែងស្ទូឌីយូសម្រាប់ផលិតវីដេអូ នៃការបង្រៀន និងស្ទូឌីយូខ្នាតធំសម្រាប់វេទិកាអប់រំ ដែលផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ដល់បុគ្គលិកសិក្សា
- រៀបចំបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ (Data Center) និងប្រព័ន្ធរក្សាទិន្នន័យ (Server) ដែលមានទំហំធំ និងមានសមត្ថភាពខ្ពស់សម្រាប់ផ្តល់សេវាអប់រំឌីជីថល ជូនដល់សិស្សានុសិស្ស និងបុគ្គលិកអប់រំទូទាំងប្រទេស
- ប្រមូល គ្រប់គ្រង វិភាគ និងប្រើប្រាស់ទិន្នន័យ ដែលទទួលបានពីការប្រើប្រាស់នៃសិស្សានុសិស្សនិងបុគ្គលិកអប់រំលើវេទិកាឌីជីថល ដើម្បីកែលម្អបន្ថែម និងធ្វើការសម្រេចចិត្តផ្នែក គោលនយោបាយសម្រាប់ការអប់រំឌីជីថល

- ជំរុញការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការអប់រំឌីជីថល និងការអប់រំ ពីចម្ងាយ ជាមួយនឹងការបណ្តុះបណ្តាលលើអក្ខរកម្មឌីជីថល
- ផ្តល់ឱកាសសម្រាប់បុគ្គលិកអប់រំ ផ្លាស់ប្តូរបទពិសោធ កសាងសមត្ថភាព និងផលិតមាតិកាឌីជីថលសម្រាប់បម្រើដល់ការអប់រំឌីជីថល។

**ប្រការ៦.-**

មជ្ឈមណ្ឌល អ.ឌ.អ.ច. មានទីតាំងនៅក្នុងបរិវេណវិទ្យាល័យព្រះស៊ីសុវត្ថិ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

មជ្ឈមណ្ឌល អ.ឌ.អ.ច. ប្រើប្រាស់រូបសញ្ញា និងត្រា របស់ក្រសួងអប់រំ យុវជន និងកីឡា។

មជ្ឈមណ្ឌល អ.ឌ.អ.ច. ប្រើអ៊ីម៉េល ដែលមានអាសយដ្ឋាន ddecenter@moeys.gov.kh និងមានទំព័រសម្រាប់បណ្តាញសង្គម សម្រាប់បំពេញសកម្មភាពការងារ។

## ជំពូកទី២
## រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឌ.អ.ច.

**ប្រការ៧.-**

មជ្ឈមណ្ឌល អ.ឌ.អ.ច. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំដោយគណៈកម្មាធិការមួយ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - អគ្គនាយក ឬ អគ្គនាយករង | សមាជិក |
| - ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | សមាជិក |
| - ប្រធាននាយកដ្ឋានកុមារតូច | សមាជិក |
| - ប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |
| - ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | សមាជិក |
| - ប្រធាននាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| - ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| - ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| - ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | សមាជិក |
| - ប្រធាននាយកដ្ឋានអប់រំពិសេស | សមាជិក |
| - ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងក្រឹត្យការ | សមាជិក |
| - ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| - ប្រធាននាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | សមាជិក |

សមាសភាពជាក់ស្តែង នៃគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឌ.អ.ច. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអាចបន្ថែមសមាសភាពតាមការចាំបាច់។

**ប្រការ៨.-**

គណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល ស.អ.ឱ.អ.ច. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- តម្រង់ទិសផ្នែកគោលនយោបាយ និងការសម្រេចចិត្តផ្នែកយុទ្ធសាស្ត្រលើដំណើរការនៃមជ្ឈមណ្ឌល អ.ឱ.អ.ច.
- ពិនិត្យ កែលម្អ និងសម្រេចលើផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការចំណាយរបស់មជ្ឈមណ្ឌល អ.ឱ.អ.ច.
- ពិនិត្យ និងសម្រេចលើទម្រង់ និងដំណើរការ នៃវេទិកាឌីជីថលគ្រប់ប្រភេទ និងយន្តការនៃការអប់រំពីចម្ងាយ ដែលរៀបចំដោយមជ្ឈមណ្ឌល អ.ឱ.អ.ច.
- ពិនិត្យ និងសម្រេចលើទម្រង់ និងរូបភាពនៃមាតិកាឌីជីថល ដែលនឹងត្រូវបង្ហោះនិងចែកចាយលើវេទិកាឌីជីថល និងយន្តការ នៃការអប់រំពីចម្ងាយ
- ត្រួតពិនិត្យ កែលម្អ និងអនុម័តលើវិធីសាស្ត្របង្រៀនបែបថ្មី ដែលត្រូវប្រើប្រាស់នៅក្នុងការផលិតមាតិកាឌីជីថល សម្រាប់បង្ហោះ និងផ្សព្វផ្សាយលើវេទិកាឌីជីថល
- សម្របសម្រួលជាមួយ ក្រសួង ស្ថាប័នផ្សេងៗ ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន ដើម្បីកៀរគរថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌល អ.ឱ.អ.ច.
- កៀរគរធនធានពីគ្រប់ប្រភព ដើម្បីអនុវត្តការអប់រំឌីជីថល និងការអប់រំពីចម្ងាយ។

**ប្រការ៩.-**

គណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. ត្រូវមានកិច្ចប្រជុំតាមការចំបាច់ និងតាមការកោះប្រជុំរបស់ប្រធានគណៈកម្មាធិការ។ នីតិវិធី នៃការធ្វើសេចក្តីសម្រេចរបស់អង្គប្រជុំ និងរបៀបរបបបំពេញការងាររបស់គណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង ដោយអនុលោមទៅតាមបែបបទរដ្ឋបាលដែលមានជាធរមាន នៃក្រសួងអប់រំ យុវជន និងកីឡា។

ប្រធានគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ ឬវិស័យឯកជន មកចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. តាមការចាំបាច់។

ប្រធានគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. អាចអញ្ជើញសាស្ត្រាចារ្យ ឬ អ្នកជំនាញបច្ចេកទេសជាតិ ឬ អន្តរជាតិ មកចូលរួមក្នុងដំណើរការពិនិត្យវាយតម្លៃ ផ្តល់យោបល់ និងកែលម្អ លើការបំពេញតួនាទីនិងភារកិច្ចនៃមជ្ឈមណ្ឌល អ.ឱ.អ.ច. តាមការចាំបាច់។

**ប្រការ១០.-**

កំណត់ហេតុ និងរបាយការណ៍ នៃកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឱ.អ.ច. ត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងត្រូវរក្សាទុកជាឯកសារ។

## ផ្នែកទី៤

## លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឱ.អ.ច.

**ប្រការ១១.-**

គណៈកម្មាធិការមជ្ឈមណ្ឌល អ.ឱ.អ.ច. មានលេខាធិការដ្ឋានមួយជាសេនាធិការ។ លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឱ.អ.ច. មានសមាសភាពដូចខាងក្រោម៖

- អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធាន

- អគ្គនាយក ឬ អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ អនុប្រធាន
- ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អនុប្រធាន
- ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន អនុប្រធាន
- មន្ត្រីជំនាញ ឬ ជំនួយការប្រតិបត្តិការ សមាជិក

សមាសភាពជាក់ស្តែងរបស់លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឌ.អ.ច. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឌ.អ.ច. អាចជ្រើសរើសជំនួយការបច្ចេកទេស មន្ត្រីកិច្ចសន្យា និងមន្ត្រីស្ម័គ្រចិត្ត តាមគោលការណ៍ជាក់ស្តែងពីក្នុងចំណោមមន្ត្រីក្របខណ្ឌ និងមន្ត្រីកិច្ចសន្យា ដែលមានស្រាប់។

**ប្រការ១២.-**

លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឌ.អ.ច. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឌ.អ.ច.
- រៀបចំ និងរក្សាទុកកំណត់ហេតុ និងរបាយការណ៍ នៃកិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឌ.អ.ច.
- រៀបចំសេចក្តីព្រាង នៃវេទិកាឌីជីថល និងគ្រប់គ្រងលើដំណើរការទាំងមូលនៃវេទិកាឌីជីថលសម្រាប់ដំណើរការ នៃការអប់រំពីចម្ងាយ
- ត្រួតពិនិត្យលើខ្លឹមសារមាតិកាឌីជីថល ដែលត្រូវបង្ហោះ និងចែកចាយលើវេទិកាឌីជីថល
- គ្រប់គ្រងដំណើរការស្ទូឌីយោសម្រាប់ការផលិត ការកាត់ត និងការរៀបចំមាតិកាឌីជីថល
- គ្រប់គ្រងលើប្រព័ន្ធ Server និងមជ្ឈមណ្ឌលទិន្នន័យ
- រៀបចំផែនការសកម្មភាព ផែនការថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុនៃមជ្ឈមណ្ឌល អ.ឌ.អ.ច
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ សម្រាប់លើកកម្ពស់ការយល់ដឹង នៃការអប់រំឌីជីថល និងការអប់រំពីចម្ងាយ
- សម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន ដើម្បីកៀរគរថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌល អ.ឌ.អ.ច.
- អនុវត្តសកម្មភាពផ្សេងទៀតដែលប្រធានគណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឌ.អ.ច.ប្រគល់ជូន។

## ផ្នែកទី៣
## ប្រភពធនធានសម្រាប់មជ្ឈមណ្ឌល អ.ឌ.អ.ច.

**ប្រការ១៣.-**

ប្រភពធនធាននៃមជ្ឈមណ្ឌល អ.ឌ.អ.ច. បានមកពីប្រភពចំណូលស្របច្បាប់ ដែលមកពី៖

- ថវិកា នៃរាជរដ្ឋាភិបាលកម្ពុជា
- អំណោយ ថវិកាជំនួយ សម្ភារ ឧបករណ៍ ពីដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជន
- ធនធានផ្សេងៗ ទៀត។

**ប្រការ១៤.-**

ថវិកា នៃមជ្ឈមណ្ឌល អ.ឌ.អ.ច. ដែលមានប្រភពពីថវិកា នៃរាជរដ្ឋាភិបាលត្រូវរក្សាទុកក្នុងអនុគណនីរបស់នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ១៥.-**

ថវិកាចំណាយសម្រាប់ដំណើរការ និងសកម្មភាពគណៈកម្មាធិការគ្រប់គ្រង និងលេខាធិការដ្ឋាន មជ្ឈមណ្ឌល អ.ឧ.អ.ច. ត្រូវស្ថិតនៅក្នុងផែនថវិកាចំណាយប្រចាំឆ្នាំ នៃមជ្ឈមណ្ឌល អ.ឧ.អ.ច. និងស្ថិតនៅក្នុង នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ជាអង្គភាពថវិកា។

**ប្រការ១៦.-**

នីតិវិធី នៃការគ្រប់គ្រងនិងការប្រើប្រាស់ថវិកានៃមជ្ឈមណ្ឌល អ.ឧ.អ.ច. ត្រូវអនុលោមទៅតាមបែបបទ ហិរញ្ញវត្ថុជាធរមាន។

ការទូទាត់ថវិកាមជ្ឈមណ្ឌល អ.ឧ.អ.ច. ដែលមានប្រភពពីថវិកាពជរដ្ឋាភិបាល ត្រូវធ្វើអនុលោមកម្មទៅ តាមនីតិវិធីទូទាត់ជាធរមាន។

ការទូទាត់ថវិកាមជ្ឈមណ្ឌល អ.ឧ.អ.ច. ដែលមានប្រភពពីដៃគូអភិវឌ្ឍ សប្បុរសជន ឬពីប្រភពផ្សេងៗ ទៀតត្រូវធ្វើអនុលោមកម្មទៅតាមនីតិវិធីទូទាត់ជាធរមាន ឬ យោងតាមការស្នើសុំ ឬ តាមកិច្ចព្រមព្រៀងជាមួយ ភាគីជាដៃគូ។

**ប្រការ១៧.-**

រាល់ឯកសារពាក់ព័ន្ធទាក់ទងនឹងការប្រើប្រាស់ និងការចំណាយថវិកាមជ្ឈមណ្ឌល អ.ឧ.អ.ច. ដោយ គណៈកម្មាធិការគ្រប់គ្រងមជ្ឈមណ្ឌល អ.ឧ.អ.ច. លេខាធិការដ្ឋានមជ្ឈមណ្ឌល អ.ឧ.អ.ច. និងអ្នកទទួលថវិកា មជ្ឈមណ្ឌល អ.ឧ.អ.ច. ត្រូវរក្សាទុកសម្រាប់ជាកម្មវត្ថុ នៃសវនកម្ម។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៩.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការដ្ឋាន ប្រធានអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តប្រកាស នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ១៩ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន